**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

## ពីការព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និងក្រុមហ៊ុន ព្រីនសៀរីហ្សត (អាម៉ាន់សារ៉ា)

កាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២១ វេលាម៉ោង០២ និង ៣០នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន ក្រុមហ៊ុន **ព្រីនសៀរីហ្សត (អាម៉ាន់សារ៉ា)** មានអាសយដ្ឋានស្ថិតនៅ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

**<u>សមាសភាពចូលរួមក្នុងអង្គប្រជុំមាន៖</u>**

| **តំណាងភាគីនិយោជក** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក Rutherford Thomas William | នាយកសណ្ឋាគារ | ០១២៤២២៣៣៣ |
| អ្នកស្រី អឿន សុវណ្ណា | ប្រធានផ្នែកធនធានមនុស្ស | ០៩២៩៩០៥៩៣ |

| **ខ. តំណាងភាគីកម្មករនិយោជិត** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក កែ សំរា | ប្រតិភូបុគ្គលិកពេញសិទ្ធិ | ០១២៩៨១៤៨៤ |
| លោកស្រី ហុងរដ្ឋា | ប្រតិភូបុគ្គលិកជំនួយ | ០១១៩៩២៤០០ |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធទៅនឹងការព្យួរកិច្ចសន្យាការងារឲ្យបានសមស្របតាមសេចក្តីណែនាំលេខ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេចក្តីប្រកាសពត៌មានស្តីអំពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីវិធានការបន្ថែមដើម្បីគ្រប់គ្រងផលប៉ះពាល់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចនៅក្នុងបរិការណ៍នៃវិបត្តិ, ការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងកំឡុងនិងក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩(ជុំទី ៨ថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២១) ភាគីទាំងពីរបានឯកភាពយល់ព្រមព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតចំនួន៦៧នាក់ក្នុងរយៈពេល៥៦ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ខែមេសាឆ្នាំ២០២១ ដល់ថ្ងៃទី៣១ខែឧសភាឆ្នាំ២០២១ ដោយទទួលបាននូវប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ៤០ដុល្លា អាមេរិក ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ ដោយសារតែក្រុមហ៊ុនបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺ COVID-19 ធ្វើឲ្យបាត់បង់ប្រាក់ចំណូលហើយបង្ខំចិត្តព្យួរកិច្ចសន្យាការងាររបស់និយោជិតមួយរយៈ។សំរាប់ក្រុមហ៊ុន មានលទ្ធភាពក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមទៅដល់កម្មករនិយោជិតក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះចំនួន៣០%នៃប្រាក់ខែគោលក្នុងខែនីមួយៗ។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ០៤ និង ៣០នាទី រសៀល ថ្ងៃ ខែ ឆ្នាំដដែល ដោយមានការចុះហត្ថលេខា ព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម៖

តំណាងភាគីនិយោជក
ហត្ថលេខា/ស្នាមមេដៃ

លោក Rutherford Thomas William
នាយកសណ្ឋាគារ

អ្នកស្រី អឿន សុវណ្ណា
ប្រធានផ្នែកធនធានមនុស្ស

តំណាងភាគីកម្មករនិយោជិត
ហត្ថលេខា/ស្នាមមេដៃ

លោក កែ សំរា
ប្រតិភូបុគ្គលិកពេញសិទ្ធ

លោកស្រី ហុង រដ្ឋា
ប្រតិភូបុគ្គលិកជំនួយ